# សេចក្តីប្រកាសរួម ស្តីពីជំងឺផ្តាសាយជ្រូក

## រវាងក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក

## ថ្ងៃទី ២៧ មេសា ឆ្នាំ ២០០៩

បច្ចុប្បន្ននេះនៅប្រទេសម៉ិកស៊ិចកូ និង សហរដ្ឋអាមេរិកកំពុងមានការរាតត្បាតជំងឺផ្តាសាយជ្រូក ដែលជាជំងឺផ្លូវដង្ហើមដែលមានកំរិតធ្ងន់ខ្ពស់នៅក្នុងចំណោមសត្វជ្រូក ចំលងមកពីវីរុសផ្តាសាយប្រភេទ អា ។ ជាធម្មតាមេរោគនេះកើតមានតែទៅលើសត្វជ្រូក ប៉ុន្តែអាចចំលងពីមនុស្សទៅមនុស្សបាន ។ នេះជាមេរោគដែលមានការព្រួយ បារម្ភណ៏ ពីព្រោះវាអាចផ្លាស់ប្តូររូបរាង និង អាចវិវត្តន៏ទៅជាមានការចំលងពី មនុស្សទៅមនុស្ស ។

មជ្ឈមណ្ឌលការពារនិងប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក បានប្រកាសពីការបញ្ជាក់ដោយលទ្ធផលមន្ទីរពិសោធន៏សរុបចំនួន ២០ ករណី នៃជំងឺផ្តាសាយជ្រូកដែលបានកើតលើមនុស្ស ចំលងដោយអនុប្រភេទ A/H1N1 ។ ករណីទាំងនេះបានកើតឡើងនៅទីក្រុង ញូវយ៉ក, តិចសាស, កានសាស, កាលីហ្វូញ៉ា និង អូហៃយ៉ូ

លើសពីនេះ នៅប្រទេសម៉ិកស៊ិចកូ រដ្ឋាភិបាលក៏បានបញ្ជាក់ចំនួន១៨ករណីលើមនុស្សមានជំងឺផ្តាសាយជ្រូកដោយអនុប្រភេទ A/H1N1 ។ ការអង្កេតស្រាវជ្រាវកំពុងបន្ត ដើម្បីកំនត់នូវទំហំនៃការរាតត្បាត និងភាពធ្ងន់ធ្ងររបស់វា ។ គេបានរកឃើញករណីសង្ស័យនៅក្នុងរដ្ឋចំនួន ១៩ ក្នុងចំណោម ៣២ រដ្ឋ ។

ដោយសារមានការកើនឡើងនៃការធ្វើដំណើរ ការរាតត្បាតនៃមេរោគនេះអាចចំលងទៅប្រទេសដទៃទៀត. ប្រទេសពីរផ្សេងទៀតបានរាយការណ៏ពីការរកឃើញករណីសង្ស័យ ប៉ុន្តែមិនទាន់បញ្ជាក់ដោយមន្ទីរពិសោធន៏នៅឡើយ ។ រហូតដល់ថ្ងៃនេះ ពុំទាន់មានការរកឃើញករណីជំងឺនេះនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ។

លោកវេជ្ជ.ម៉ាហ្គារ៉េត ចាន់ អគ្គនាយកនៃអង្គការសុខភាពពិភពលោក បានប្រកាសពីស្ថានភាពនេះជាភាពអាសន្នផ្នែកសុខភាពសាធារណៈដែលមានការបារម្ភណ៏ជាអន្តរជាតិ ។ អង្គការសុខភាពពិភពលោកផ្តល់ដំបូន្មានដល់ក្រសួងសុខាភិបាល ឱ្យពង្រឹងការ តាមដានជំងឺឆ្លង ។ នៅគ្រឹះស្ថានសុខាភិបាល សូមឱ្យរាយការណ៏នូវរាល់ករណីជំងឺផ្តាសាយខុសធម្មតា ទៅក្រសួងសុខាភិបាល ។ អង្គការសុខភាពពិភពលោកប្រចាំនៅតំបន់ប៉ាស៊ីហ្វិកខាងលិច នឹងធ្វើការតាមដានយ៉ាងជិតស្និទ្ធ នូវស្ថានភាពនៅក្នុងតំបន់ និង បានចាប់ផ្តើមដំណើរការប្រកាសការរាតត្បាត និង ឧបករណ៏គ្រប់គ្រងភាពអាសន្ន ។

ប្រទេសកម្ពុជា កំពុងបង្កើនការតាមដានជំងឺផ្តាសាយធំ នៃជំងឺផ្លូវដង្ហើមមិនធម្មតានៅក្នុងមន្ទីរពេទ្យ នៅមណ្ឌលសុខភាព និង អាកាសយានដ្ឋាន ។ ទោះពុំទាន់មានវ៉ាក់សាំងបង្ការជំងឺនេះក៏ដោយ ប៉ុន្តែយើងអាចមានលទ្ធភាពធ្វើការព្យាបាលដោយឱសថ ទោះបីជាពុំទាន់ដឹងច្បាស់លាស់ពីភាពសមស្របរបស់វានៅឡើយ ។ ប្រទេសកម្ពុជាបានរៀបចំស្តុក ដែលបានមកពីប្រភពផ្សេងៗ ក្នុងនោះមាន ឱសថសំរាប់ព្យាបាល និងកំពុងរកជំនួយបន្ថែមពីតំបន់ក្នុងករណីចាំបាច់ ។

ប្រទេសកម្ពុជាមានផែនការសំរាប់ឆ្លើយតបទៅនឹងជំងឺរាតត្បាតជាសកល ។ ស្ថាប័នទាំងឡាយ ដែលមានផែនការរបស់ខ្លួនត្រូវធ្វើបច្ចុប្បន្នភាពផែនការទាំងនោះ ហើយពិនិត្យគេហទំព័រ របស់អង្គការសុខភាពពិភពលោក ដើម្បីធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ : http://www.who.int/csr/disease/swineflu/en/index.html

ក្រសួងសុខាភិបាលសំណូមពរដល់ប្រជាជន ដែលត្រលប់មកពី ប្រទេសកំពុងរាតត្បាត នៅក្នុងកំឡុងពេល ៧ថ្ងៃ ដែលមានរោគសញ្ញាដូចជា គ្រុនក្តៅ ៣៨ អង្សា ឬ លើស, រួមជាមួយក្អក, ឈឺក ឬ ពិបាកដកដង្ហើម សូមទាក់ទងគ្រឹះស្ថានសុខាភិបាលដែលជិតបំផុត ។

មន្ត្រីសុខាភិបាល និង សាធារណៈជន សូមរាយការណ៍ទៅប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងសុខាភិបាល តាមរយៈទូរស័ព្ទ **០១២ ៤៨៨ ៩៨១** និង **០៨៩ ៦៦៩ ៥៦៧** ។

**សំរាប់ពត៌មានបន្ថែមសូមទាក់ទង:**

**-ក្រសួងសុខាភិបាល**

. វេជ្ជ. សុខ ទូច លេខទូរស័ព្ទ: (+៨៥៥) ១២ ៨៥៦ ៨៤៨ ឬ

. វេជ្ជ. លី សូវ៉ាន់ លេខទូរស័ព្ទ: (+៨៥៥)១២ ៨២៥ ៤២៤

**-អង្គការសុខភាពពិភពលោក:**

. វេជ្ជ. ម៉ៃយល អូឡៅរី លេខទូរស័ព្ទ : (+៨៥៥) ១២ ៩៧៦ ៩៧៦ ឬ

. វេជ្ជ. អាហ្គារី នីម៉ា លេខទូរស័ព្ទ: (+៨៥៥) ០១២ ៤៤៣ ៨៧៧